ការសំភាសន៍របស់បងស្រី រ័ត្ន ណារ៉ាន់

ក៖ អ្នកសម្ភាសឈ្មោះថា ជាង ស៊ីអ៊ារ ខ៖ អោយទទួលការសម្ភាសឈ្មោះ រ័ត្ន ណារ៉ាន់

<u>ការសង្ខេបប្រវត្តិរបស់ បងស្រី រ័ត្ន ណារ៉ាន់</u>

បងស្រី រ័ត្ន ណារ៉ាន់ មានអាយុឆ្នាំ នៅក្នុងឆ្នាំ២០១៨ មានភេទស្រី មានទីលំនៅបច្ចុប្បន្ននៅ ភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប

ក៖
សូមជំរាបសួរដល់បងស្រីដែរបងស្រីបានអនុញ្ញាតិអោយរូបនាងខ្ញុំមកសម្ភាសបងស្រីដែរទាក់ទងពី ប្រវត្តិរបស់បង ហើយរូបនាងខ្ញុំជ្រាល់ឈ្មោះអេង ដាលីនហើយថ្ងៃនេះខ្ញុំមកសម្ភាសបងថ្ងៃនេះ ថ្ងៃទី២៥ ខែ១ ឆ្នាំ២០១៩ អើហើយបងយល់ព្រមអនុញ្ញាតិអោយរូបនាងខ្ញុំមកសម្ភាសបងទេបង?
ខ៖ ចា.....!
ក៖ អើហើយអើបងមានឈ្មោះអីដែរបង?
ខ៖ ឈ្មោះ ណារ៉ាន់។
ក៖ ត្រកូលអីដែរបង?
ខ៖ រ័ត្ន ណារ៉ាន់។
ក៖ រ៉ាត់ ណារ៉ាន់?
ខ៖ រ័ត្ន ណារ៉ាន់។
ក៖ រ័ត្ន ណារ៉ាន់?
ខ៖ ហ្នឹងហើយ.....!
ក៖ ចា!បងហើយចុះអធ្យាស្រ័យហើយចុះនៅភូមិហ្នឹងគេហៅភូមិអី ឃុំអី ស្រុកអីដែរ?
ខ៖ ភូមិបឹងកុក២ ឃុំបឹងកុក សង្កាត់បឹងកុក។
ក៖ ខេត្ត.....?
ខ៖ ខេត្តកំពង់ចាម។
ក៖ ខេត្តកំពង់ចាម ចឹងបងមានអាយុប៉ុន្មានឆ្នាំហើយបង?
ខ៖ សែសិបប្រាំពីរ។
ក៖ បងដឹងថាបងកើតឆ្នាំណាអត់?
ខ៖ កើត១៩៧៦។
ក៖ ១៩៧៦.....?
ខ៖ ចា.....!
ក៖ បងអាយុសែសិបប្រាំពីរ?
ខ៖ សែសិបប្រាំពីរ។
ក៖ អើ.....?
ខ៖ បើរាប់ខែវាឆ្នាំ.....?
ក៖ អើបងកើតឆ្នាំ១៩៧២?
ខ៖ ហ្នឹងហើយ.....!
ក៖ អើ.....?
ខ៖ ប៉ុនយើងអោយគេដាក់ចូលរៀនគេដំឡើងអាយុ។
ក៖ អ៎!គេដំឡើងអាយុចាបង!
ខ៖ គេដំឡើងអាយុអោយយើងបានចូលរៀនចឹងហាសគេដាក់៧៦។
ក៖ ចា!គេដាក់៧៦?
ខ៖ ចា.....!
ក៖ ចា!បងអើហើយបងមានកូនប៉ុន្មាននាក់បង?
ខ៖ បីមានកូនបីនាក់។
ក៖ មានកូនបីនាក់ កូនទីមួយឈ្មោះអីបង?
ខ៖ កូនទីមួយឈ្មោះវ៉ែន សុខជា។
ក៖ ចុះទីពីរ.....?

ខ៖ ទីពីរវ៉ែន សម្បត្តិ ទីបីវ៉ែន សុខទី។
ក៖ វ៉ែន សុខទី?
ខ៖ ចា៎.....!
ក៖ ហើយចុះឥឡូវកូនបងដែរធំជាងគេប៉ុន្មានឆ្នាំហើយបង?
ខ៖ អើឆ្នាំកោរ។
ក៖ អាយុប៉ុន្មានឆ្នាំទៅ?
ខ៖ អាយុម្ភៃជាងហើយ។
ក៖ អាយុម្ភៃជាងហើយ?
ខ៖ ចា៎.....?
ក៖ ហើយចុះកូនបងនៅណាទៅបង?
ខ៖ កូននៅម៉ាឡេ។
ក៖ ម៉ាឡេ.....?
ខ៖ ទៅម៉ាឡេ។
ក៖ អ៊ូ!ទៅតាំងពីឆ្នាំណាបង?
ខ៖ ទៅតាំងពីពីរអើទៅតាំង២០១០។
ក៖ អ៊ូ!ហើយចុះដែរមកផ្ទះទេបង?
ខ៖ ដល់ខែបីលីវាថាអោយលេងនេះដឹងម៉េច។
ក៖ ចឹង.....?
ខ៖ ចាំមើលសិន។
ក៖ ចា៎!ចុះបងមានឈ្មោះហៅក្រៅទេ?
ខ៖ អត់មានផង។
ក៖ គេចំណាំតែហៅបងថាម៉េចទៅ?
ខ៖ ហៅតែមួយ។
ក៖ ហៅអីគេទៅ?
ខ៖ ហៅណាវ៉ាន់ៗ។
ក៖ អ៊ូ!ហៅណាវ៉ាន់ៗណោះ?
ខ៖ ចា៎.....!
ក៖ ចា៎!ហើយចុះ.....?
ខ៖ ក្មួងបញ្ជីម៉េចឈ្មោះក្រៅចឹង។
ក៖ អ៊ូ!ហើយនៅពីក្មេងអត់មានហៅឈ្មោះអីដែរ?
ខ៖ អត់មានផង។
ក៖ ចា៎!ចឹងបងឆ្នាំបងឆ្នាំជាច័ន្ទគតិហាសដូចជាជូត ឆ្លូវ ខាល ថោះអ៊ុឆ្នាំអី?
ខ៖ ឆ្នាំជូត.....។
ក៖ ជូត.....?
ខ៖ ជូត.....!
ក៖ ចា៎!អាយុសែសិបជ្រាំពីរឆ្នាំណោះ?
ខ៖ ចា៎.....!
ក៖ ចា៎!ឆ្នាំជូតហើយចុះបងអើកើតនៅភូមិណាដែរស្រុកកំណើត?
ខ៖ កើតនៅភូមិអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
ក៖ ចា៎!ភូមិអំពិល?
ខ៖ ចា៎!ភូមិអំពិល ឃុំអំពិល។
ក៖ ចា៎!ហើយចុះបងមានបងប្អូនប៉ុន្មាននាក់?
ខ៖ បងប្អូនជ្រាំបីនាក់។
ក៖ ហើយចុះបងជាកូនទីប៉ុន្មាន?
ខ៖ បងខ្ញុំអើកូនទីបួន។
ក៖ កូនទីបួន?
ខ៖ ទីបួន ទីបី?
ក៖ អ៊ូ!ទីបីហោស?
ខ៖ មើលរាប់មើល។
ក៖ រាប់មកអាចរាប់បានតើ?
ខ៖ ទីបួន កូនទីបួន។

ក៖ ទីបួនហោស?
ខ៖ កូនទីបួន។
ក៖ ចឹងបងអាចរៀបរាប់ឈ្មោះបងប្អូនទាំងអស់បានទេ?
ខ៖ បានតើ.....!
ក៖ រៀបរាប់មក?
ខ៖ បងទីមួយឈ្មោះណារីម ទីពីរឈ្មោះណារ៉េត
ប៉ុនរ៉េតណុងស្លាប់បាត់ហើយគ្រោះថ្នាក់ចរាចរណ៍ ដល់ពេលកូនទីបីណារ៉ា
ទីបួនខ្ញុំណារ៉ាន់។
ក៖ ណារ៉ាន់.....?
ខ៖ ដល់ពេលទីប្រាំណារុង ណារុងរួចមកណារ៉ន ណារ៉នរួចណារ៉ែន ណារ៉ែនរួចណារី
ណារីរួចណារីអស់ហើយ។
ក៖ អស់ហើយទាំងអស់ប៉ុន្មាននាក់ប្រាំបី?
ខ៖ ប្រាំបី.....!
ក៖ ប្រាំបីនាក់ហើយថាអើ.....?
ខ៖ ប្រាំបីនាក់ហើយអើនៅប្រាំពីរ។
ក៖
នៅសល់ប្រាំពីរថាហើយចុះអើបងហ្នឹងបងប្អូនបងមានកាលនៅពីក្មេងតែងតែចូ
លចិត្តធ្វើអីបងៗប្អូន បងប្អូនបងឯងទាំងអស់គ្នាហាសដូចថា.....?
ខ៖ គ្មានធ្វើអីផងជំនាន់ណុងដាំត្រកួន
ដាំត្រកួនលក់ទៅចូកកំពិសចូកអីនៅបឹងហ្នឹង។
ក៖ ចឹង.....!
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយដាំហើយ ហើយយកទៅលក់ទាំងអស់គ្នាហោស?
ខ៖ ចា.....!
ក៖ យកទៅលក់នៅណាបង?
ខ៖ យកទៅលក់ជួនកាលលក់ទីផ្សារទៅ ជួនកាលទៅព្រៃទទឹង។
ក៖ ហើយចុះគ្រួសារបងអត់មានស្រែអីទេណោះ?
ខ៖ អត់.....!
ក៖ ដាំតែបន្តែលក់?
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយទៅអត់មានទៅស៊ីឈ្នួលអីកាប់ដំឡងកាប់អីទាំងអស់គ្នាមានទេ?
ខ៖ អត់.....!
ក៖ អត់ដែរទេណោះ?
ខ៖ ចា.....!
ក៖ ហើយទៅឥឡូវបងប្អូនរបស់បងនៅណាទៅបង?
ខ៖ បងប្អូននៅដល់ពេលគេបែកផ្ទះទៅជួនកាលគេទៅនៅលង្វែងខ្លះទៅ
ទៅនៅកំពង់ចាមខ្លះទៅមណ្ឌល គីរីខ្លះទៅ ទៅខាងត្បូងឃ្មុំខ្លះទៅ។
ក៖ មានអីទៀតអត់?
ខ៖ អត់.....!
ក៖ ចា!ហើយចង់សួរពីម្តាយរបស់បងឈ្មោះអីដែរ?
ខ៖ ម្តាយឈ្មោះតាន់ ហួកីន។
ក៖ ឈ្មោះគាត់ពិរោះមើស?
ខ៖ ចាស់ជរាហើយ។
ក៖ ឈ្មោះពិរោះម៉េចតាន់ ហួកីនដូចតួកូរ៉ ឈ្មោះតាន់ ហួកីន?
ខ៖ តាន់ ហួកីន។
ក៖ ចា!ហើយគាត់មានមុខរបរអីម្តាយ?
ខ៖ គាត់អើពីដើមមកគាត់ធ្វើការរោងចក្រឥឡូវគាត់អាត្រែតហើយ។
ក៖ អ៎!ហើយឥឡូវគាត់នៅណាទៅបង?
ខ៖ នៅផ្ទះនៅអ៊ីលិចហោស។
ក៖ នៅអ៊ីលិចហោស?
ខ៖ ចា.....!

ក៖ នៅជិតវត្តហ្នឹងដែរហោស?
ខ៖ នៅឆ្ងាយពីវត្តដែរទៅផ្លូវកណ្តាលទៅផ្លូវបន្ទាយកណ្តាល។
ក៖ តាន់ ហួភីន?
ខ៖ ចា៎!តាន់ ហួភីន។
ក៖ ហើយចុះឪពុកបងឈ្មោះអីដែរ?
ខ៖ ឪពុកស្លាប់ហើយ។
ក៖ ស្គាល់ឈ្មោះគាត់ទេ?
ខ៖ ស្គាល់.....!
ក៖ ឈ្មោះអីគេ?
ខ៖ កែវ រនណៃ។
ក៖ កែវ រនណៃ?
ខ៖ កែវ រនណៃ។
ក៖ កែវ រន ណៃ?
ខ៖ ហ្នឹងហើយ.....!
ក៖ ហ៊ឺ!ចាំម៉ាក់បងឈ្មោះពិរោះៗហាសណោះឈ្មោះកែវ រនណៃណោះ?
ខ៖ ចា៎.....!
ក៖ ហើយចុះគាត់មានគាត់ស្លាប់អាយុប៉ុន្មានបង?
ខ៖ គាត់ស្លាប់តាំងពីអាយុចិតបួនម៉ែស។
ក៖ ចិតបួន.....?
ខ៖ ចា៎.....!
ក៖ ហើយចុះម្តាយរបស់បងឥឡូវអាយុប៉ុន្មាន?
ខ៖ អើឥឡូវអាយុចិតបួនហើយ។
ក៖ ម៉ាក់ហាសម្តាយហាស?
ខ៖ ចា៎!អាយុចិតបួន។
ក៖ ហើយចុះម្តាយស្រុកកំណើតនៅណា?
ខ៖ ស្រុកកាសាក់ ស្រុកកំណើតនៅភូមិអំពិល។
ក៖ នៅភូមិអំពិល?
ខ៖ ចា៎.....!
ក៖ ហើយចុះបើឪពុកវិញហាស?
ខ៖ អត់ស្គរដឹងដែរ។
ក៖ អត់ដឹងទេហោស?
ខ៖ ចា៎!នៅកំពង់ថ្មហិ ហ៊ីយរឿលែងស្គាល់ស្រុកកំណើតឪពុកហើយ។
ក៖ នៅណាបង?
ខ៖ ចេះតែមានម៉ងហាសបងប្អូននៅកំពង់ថ្មហិ
នៅជាមួយអ៊ុំហ៊ួយអ៊ុំអីហិនៅកំពង់ថ្ម។
ក៖ នៅកំពង់ថ្មហោស?
ខ៖ គាត់នៅខាងកំពង់ថ្ម។
ក៖ អ៊ូចា៎.....!
ខ៖ នៅស្រុកបារាយណ៍។
ក៖ ចាំបង.....!
ខ៖ ខេត្តកំពង់ធំ។
ក៖ អ៊ូរចា៎.....!
ខ៖ ប៉ុនអត់ស្គាល់ភូមិ។
ក៖ អត់ស្គាល់ភូមិ?
ខ៖ ហ្នឹងហើយ.....!
ក៖ ចា៎!អត់ទេហើយចុះអើឪពុកបងស្លាប់នៅពេលបងអាយុប៉ុន្មានចាំបានទេ?
ខ៖ អាយុប៉ុន្មានទេអត់ចាំផងៗ
ក៖ អ៊ូ.....!
ខ៖ អាយុសាមសិបជ្រាំបួន។
ក៖ បងបងប្អូនគ្នាមែន?
ខ៖ ប្អូនថ្លៃ.....។

ក៖ អ៊ូ!ប្អូណាថ្លៃហោស?
ខ៖ ប្តីវាត្រូវប្អូនខ្ទុំបង្កើតថា.....។
ក៖ អ៊ូ!ចឹងហោសចឹងបានគាត់ដឹង
ហើយចុះអើឪពុកបងគាត់រកស៊ីអីគេដើម្បីចិញ្ចឹមកូនហាស?
ខ៖ គាត់ធ្វើការរោងចក្រដែរ។
ក៖ គាត់ធ្វើការរោងចក្រដែរ?
ខ៖ ចា៎.....!
ក៖ ធ្វើរោងចក្រនៅណាដែរបង?
ខ៖ រោងចក្រនៅខេត្តកំពង់ចាមហ្នឹងយើងប៉ុនគាត់អត់បានអាត្រេតទេ។
ក៖ បើម្តាយបាន?
ខ៖ ម្តាយបានអាត្រេត។
ក៖ បានអាត្រេតហ្នឹងមានន័យថាបានលុយប្រាក់ខែដែរហោស?
ខ៖ ហ្នឹងហើយបានប្រាក់ខែ។
ក៖ អ៊ូ!គាត់អាត្រេតហើយសព្វថ្ងៃហ្នឹងគាត់បានប៉ុន្មានទៅបង?
ខ៖ អត់ដឹងផង។
ក៖ ដោយសារបានតិចៗដែរហោសបង?
ខ៖ ហ្នឹងហើយអត់សូវដែរដឹង។
ក៖ អ៊ូ!មួយរយដប់ មួយរយដប់ម៉ាក់បងឯងបានមួយរយដប់ក្នុងមួយខែ
អ៊ុឡយហាសណោះបានប្រាក់អាត្រេតទៀតអើធ្វើការរោងចក្រគាត់ធ្វើយូរហើយមែនទេបង?
ខ៖ ធ្វើយូរហើយតាំងពីជំនាន់ពីដើមតាំងពីជំនាន់ក្បាញ្ចកីមានកីក្បាញ្ច
ៗអើធ្វើការស្រាប់ៗម៉ង។
ក៖ អ៊ូចឹង.....?
ខ៖ តាំងពីក្បាញ្ចក្រណាត់តាំងពីចិតតាំងពីជំនាន់អាពត
និយាយអោយចំទៅគាត់ធ្វើតាំងពីជំនាន់អាពតមក។
ក៖ ចា៎.....!
ខ៖ តាំងពីគាត់នៅក្មេងៗឥឡូវគាត់ចិតជាងហើយ។
ក៖ គាត់ធ្វើតាំងពីដើមមក?
ខ៖ ហ្នឹងហើយធ្វើតាំងពីដើម។
ក៖ ដល់ចឹងអើគេប្រធានគេលើកទឹកចិត្តណោះ?
ខ៖ ចា៎.....!
ក៖ ហើយរកស៊ីមួយហ្នឹងដើម្បីចិញ្ចឹមកូនហោសបង?
ខ៖ ចា៎.....!
ក៖ ហើយចុះបងបានចូលរៀនអីទេ?
ខ៖ បានចូលរៀន។
ក៖ ចូលរៀនបានថ្នាក់ទីប៉ុន្មានបង?
ខ៖ បានត្រឹមថ្នាក់ទីប្រាំពីរ។
ក៖ ថ្នាក់ទីប្រាំពីរហោស?
ខ៖ ចា៎.....!
ក៖ បងប្អូនទាំងអស់បានចូលរៀនទាំងអស់ហោសបង?
ខ៖ បានចូលរៀនទាំងអស់។
ក៖ អ៊ូ.....!
ខ៖ គ្រាន់ថារៀនមិនបានច្រើនរៀនបានតិចៗចឹងទៅឈប់ចឹងទៅ។
ក៖ ចឹងហើយចុះអើចឹងបងមានចងចាំឈ្មោះបងប្អូនជីដូនមួយអីទេ?
ខ៖ អត់ចាំផង។
ក៖ អត់ចាំទេហោស?
ខ៖ ចា៎.....!
ក៖ បងប្អូនជីដូនមួយបងឯងហាស?
ខ៖ អត់ចាំទេ។

ក៖
អ៎!ចឹងហើយចុះអើបងមានចាំឈ្មោះយាយរឺមួយក៏តាខាងឪពុកខាងម្តាយទេយាយតាហាស?
ខ៖ យាយតាខាងឪពុកយាយឈ្មោះយាយចិនដល់ពេលតាឈ្មោះតារ៉ត។
ក៖ តារ៉ត.....?
ខ៖ ចា.....!
ក៖ ហើយចុះខាងម្តាយ?
ខ៖ ខាងម្តាយអើខាងម្តាយឈ្មឡតាហូ តាហូហើយម្តាយយាយហាង។
ក៖ អើចាំណោះ?
ខ៖ ចាំ.....!
ក៖ ហើយចុះគាត់រស់នៅណាទៅតាយាយចឹងហាស?
ខ៖ គាត់ស្លាប់អស់ហើយ។
ក៖ តែពេលកាលគាត់នៅរស់គាត់នៅណាដែរ?
ខ៖ នៅកំពង់ថ្ម។
ក៖ នៅកំពង់ថ្មទាំងអស់?
ខ៖ ហ្នឹងហើយ.....!
ក៖ ទាំងខាងឪពុកទាំងខាងម្តាយ?
ខ៖ ហ្នឹងហើយទាំងសងខាង។
ក៖ អ៎!គាត់រស់នៅហ្នឹងហើយចុះបងកើតទាន់ជំនាន់តាយាយទេ
តាយាយរបស់បងហាស?
ខ៖ កើតទាន់តើ.....!
ក៖ កើតទាន់ហោសបង?
ខ៖ ចា!កើតទាន់នៅកំពស់ហ្នឹង។
ក៖ ចឹងហើយ.....?
ខ៖ នៅវ័យកុមារ។
ក៖ វ័យកុមារហោស?
ខ៖ ចា.....!
ក៖
បងហើយចុះបងមានចាំរឿងតាយាយទេថាតាយាយពីដើមគាត់មានមុខរបរអីដើម្បីចិញ្ចឹមក្មួនគាត់ហាសណាស់ដែរដឹងទេ?
ខ៖ អត់អត់ដែរដឹងផង។
ក៖ ហើយអើហើយចុះក្រុមគ្រួសាររបស់បងមកនៅហ្នឹងយូរឆ្នាំនៅ?
ខ៖ ចេញមកចិតប្រាំបួន។
ក៖ ចិតប្រាំបួន?
ខ៖ ចាមកនៅ.....!
ក៖ តាំងពីបែកប៉ុលពតហោសបង?
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយចុះ.....?
ខ៖ និយាយតាឪពុកហ្នឹងហាស ខាងម៉ែហីខាងពុកចិនគាត់សំអាងការ។
ក៖ សំអាងការ?
ខ៖ ចា!គាត់សំអាងការ
ក៖ យាយរបស់បងហោស?
ខ៖ ហ្នឹងហើយ.....!
ក៖ អូបើក.....?
ខ៖ យាយខាងឪពុក។
ក៖ បើកសំអាងការ?
ខ៖ ហ្នឹងហើយបើកសំអាងការ។
ក៖
អើសម្គាសមនុស្សច្រើនហើយតែអត់ដែរមាននរណាគេបើកសំអាងការទើបមានយាយរបស់បងបើកសំអាងការ.....។
ខ៖ យាយខាងឪពុកហ្នឹងបើកសំអាងការពីដើមមក។

ក៖ អ៎!ពីដើម.....?
ខ៖ កាត់ដាច់រឿទៅដូរថាដាច់អាពតទៅគាត់សំអាងការហ្នឹង។
ក៖ ចា!ហ្នឹងហើយ
ហើយចុះបងគ្រួសាររបស់បងអើមាននរណាដែររស់នៅខេត្តផ្សេងទេដូចជាប្អូនៗអីហាសមានរស់នៅខេត្តផ្សេងទេ?
ខ៖ ប្អូនមានរស់នៅខេត្តអើមណ្ឌលគីរីមួយបងហ្នឹងទៅនៅខាងលង្វែងមួយ
ហើយចុះណោះអាពាទៅនៅត្បូងឃ្មុំហោសខាងអើស្អី.....!
ក៖
ហើយបើសិនជាអើសាច់ញាតិមានតើបងមានសាច់ញាតិរស់នៅក្រៅប្រទេសទេដូចជាថៃម៉ាឡេអី?
ខ៖ អត់មានទេមានតែកូនមួយទៅម៉ាឡេ។
ក៖ អ៎!ទៅម៉ាឡេ?
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយក្រៅពីហ្នឹងទៀតអត់មានបងប្អូនទៅទេណោះ?
ខ៖ អត់ទេអត់មានទេ។
ក៖ អ៎!ទៅម៉ាឡេទៅយូរទេ?
ខ៖ ទៅម៉ាឡេទៅយូរហើយទៅតាំងពីនេះម៉េស២០១០ម៉េស។
ក៖ កូនស្រីកំប្រុសបង?
ខ៖ កូនស្រី.....។
ក៖ ស្រីកូនរបស់បងហោស?
ខ៖ ហ្នឹងហើយ.....!
ក៖ កូនបងគេហោស?
ខ៖ កូនបង.....។
ក៖ ចា!ហើយចុះអើស្វាមីរបស់បងមានឈ្មោះអ្វីដែរបង?
ខ៖ ឈ្មោះវ៉ែន វណ្ណ ប៉ុនគាត់ស្លាប់ហើយ។
ក៖ អ៎!គាត់ស្លាប់យូរនៅបង?
ខ៖ គាត់ស្លាប់ពេលភ្ជុំហើយ។
ក៖ ភ្ជុំហើយពេលណា?
ខ៖ មួយថ្ងៃត្រូវមួយរយថ្ងៃហើយនេះខែដប់។
ក៖ អូខែដប់.....?
ខ៖ គាត់ស្លាប់ខែដប់។
ក៖ អ៎គាត់មូលហេតុអីបានគាត់ស្លាប់បង?
ខ៖ គាត់ឈឺ.....។
ក៖ គាត់ឈឺអីគេដែរបង?
ខ៖ គាត់ឈឺរោគគាត់ហ្នឹងសួតផង ថ្លើមផងក្រពះពោះវៀន។
ក៖ ចា!ហើយចុះបងដឹងថាបងរៀបការនៅពេលណាទេនៅឆ្នាំណាចាំបានទេ?
ខ៖ រៀបការអើកៅគត់។
ក៖ ឆ្នាំកៅគត់ហោស?
ខ៖ ចា.....!
ក៖ អត់ដឹងថ្ងៃអត់ដឹងអីទេហោស?
ខ៖ អត់ដឹងថ្ងៃទេដឹងតែកៅគត់។
ក៖ អ៎!កៅគត់?
ខ៖ ចា.....!
ក៖
ចឹងនៅពេលដែរបងរៀបការអើឪពុកម្តាយរបស់បងជាអ្នកផ្សំផ្គុំអោយឬមួយក៏ស្រឡាញ់គ្នាដោយចិត្ត ហ្នឹងចិត្ត?
ខ៖ ស្រឡាញ់ចិត្តហ្នឹងចិត្ត។
ក៖ អ៎!ស្រឡាញ់ចិត្តហ្នឹងចិត្តហើយ?
ខ៖ ចា.....!
ក៖ ទើបប្រាប់ឪពុកម្តាយក្រោយឬមួយក៏.....?
ខ៖ ហ្នឹងហើយ.....!

ក៖ ទើបប្រាប់ឪពុកម្តាយក្រោយហោស?
ខ៖ ចា.....!
ក៖ អើហើយពេលបងរៀបការមានអីគេខ្លះទៅពេលថ្ងៃដែរបងរៀបការហាស?
ខ៖ អត់រៀបការធំដំអីផងគ្រាប់តែសែន។
ក៖ គ្រាន់តែសែន?
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយគាត់អត់មានដូចជាអើបណ្តាការអីអោយបង.....?
ខ៖ អត់ទេអត់ទេ។
ក៖ អត់ទេហោសសែនហ្នឹងដូចជាធ្វើរបៀបម៉េចដែរបង?
ខ៖
គ្រាន់តែសែនហ្នឹងមានក្បាលជ្រូកមានអីហ្នឹងមានចាស់ទុំពីរបីនាក់ចឹងទៅណាស់
មានអាចារ្យមានចាស់ទុំពីរបីនាក់ចា.....។
ក៖ សែនចាហើយចុះអើនៅពេលចង់សួរបន្តិចហាសណាស់
ចង់សួរថាបងធ្វើម៉េចបានស្គាល់ប្តីបងហាស?
ខ៖ ទៅធ្វើការនៅភ្នំពេញ។
ក៖ បងឯធ្វើអីហើយគាត់ធ្វើអីដែរ?
ខ៖
គាត់ធ្វើខាងសន្តិសុខហើយខ្ញុំខាងកូនកាំបិតកូនអីចឹងទៅណាស់ធ្វើនៅហាងជាមួយគ្នា ទៅក៏ស្គាល់គ្នាទៅណាស់។
ក៖ ហើយក៏ស្រឡាញ់គ្នាទៅ?
ខ៖ ចា!ក៏ស្រឡាញ់គ្នាទៅរួចក៏មកនាំមកសែនមកអីចឹងទៅណាស់។
ក៖
ចា!ហើយមានអនុស្សាវរីយ៍អីគេខ្លះជាមួយគ្នាពេលអត់ទាន់ការចឹងហាសដូចមានទៅដើរលេងអីទេបង?
ខ៖ មានដែរដើរទៅណាទេនៅតែកន្លែងធ្វើការ។
ក៖ អ៎!ចឹងចុះពេលសែនពេលអីហើយពេលសែនហ្នឹងមានភ្ញៀវច្រើនទេ?
ខ៖ មានភ្ញៀវទេ។
ក៖ សែនបងប្អូនឯងហ្នឹង?
ខ៖ ហ្នឹងហើយបងប្អូនឯងហើយណាតែចាស់ទុំពីរបីនាក់ហ្នឹងហាស។
ក៖ ខាងគេអីទៅ?
ខ៖ យាយៗពីរបីនាក់អីទៅហ្នឹងហើយអត់ ខាងប្រុសអត់មានទេ។
ក៖ អ៎!គាត់កំព្រាឪក៏ម៉េច?
ខ៖ គាត់កំព្រាឪពុកម្តាយស្លាប់តាំងពីជំនាន់អាពតអស់ហើយ។
ក៖ ចា.....!
ខ៖ ចា.....!
ក៖ ហើយគាត់នៅជាមួយនរណាគេទៅ?
ខ៖ គាត់មកហាសនៅប្រវត្តិគាត់។
ក៖ អាចរៀបរាប់ប្រវត្តិគាត់បានទេ?
ខ៖ តាមប្រវត្តិគាត់គាត់នៅជាមួយប្អូន
នៅជាមួយប្អូននៅខាងកំពង់ស្ពឺអីចឹងហាសណាស់។
ក៖ ហើយគាត់.....?
ខ៖ ហើយគាត់មកធ្វើការនៅភ្នំពេញអីចឹងទៅក៏ស្គាល់។
ក៖ ហើយគាត់មានបងប្អូនប៉ុន្មាននាក់?
ខ៖ អត់សូវដែរដឹងបងប្អូនគាត់។
ក៖ ដល់ពេលគាត់ការមកនៅខាងយើងម៉ង?
ខ៖
ចា!ការហើយមិនទាន់មកនៅខាងខ្ញុំទេមកធ្វើការនៅភ្នំពេញដល់ពេលមានកូនមានអីចឹងទៅ
យកមកអោយយាយមើលអីចឹងហាសណាស់យកមកអោយយាយមើលទៅរួចទៅបានគាត់ដល់ពេលឈប់
ការងារទៅដូចថាដាច់ការងារទៅគាត់មកនៅកំពង់ចាមដែរ។

ក៖ ចឹង.....!
ខ៖ ចំ.....!
ក៖ ដាច់អាណាត់ការងារ?
ខ៖ ចំ!ដាច់អានាត់ការងារទៅមកនៅកំពង់ចាម។
ក៖
ហើយចុះពីកាលបងរៀននៅសាលាក្រៅពីភាសាខ្មែរតើបងមានភាសាអីដែរចេះទៀតទេ?
ខ៖ អត់មាន.....។
ក៖ អត់មានទេណោះ?
ខ៖ ចំ.....!
ក៖ អ៎!ហើយចុះបងអត់ចេះទេណោះ?
ខ៖ អត់.....!
ក៖ អត់ចេះនិយាយ?
ខ៖ អត់ចេះអង់គ្លេសអីអត់ចេះ។
ក៖ ហើយរៀនបានថ្នាក់ទីប៉ុន្មានបង?
ខ៖ ត្រឹមទីប្រាំពីរ។
ក៖ ហើយបឋមសិក្សាឈ្មោះអីដែរ?
ខ៖ បឋមសិក្សាទួលថ្ម។
ក៖ ចុះអនុ.....?
ខ៖ វិទ្យាល័យសីហនុ។
ក៖ អាហ្នឹងវិទ្យាល័យសីហនុ?
ខ៖ ចំ!ចូលទីប្រាំពីរចូលសីហនុ។
ក៖ សីហនុយើងនេះហោស?
ខ៖ ហ្នឹងហើយ.....!
ក៖ ចំ!នៅខេត្តខ្មុំជិះកាត់តើយើញ?
ខ៖ ហ្នឹងហើយ.....!
ក៖ បានយើញសាលាហ្នឹង!
ខ៖ អាហ្នឹងចូលទីប្រាំពីរទៅរៀនខាងហ្នឹង។
ក៖ អ៎!សាលាហ្នឹងមានតាំងពីដើមហើយណោះ?
ខ៖ ចំ!មានតាំងពីបែកបែកជាង។
ក៖ ហើយបងចូលរៀនជំនាន់ណា?
ខ៖ ចូលរៀនជំនាន់បែក
បែកគត់បែកបីដល់ពេលយួនទៅស្រុកវិញបែកប្រាំដល់ពេលកៅគត់ខ្មុំសែន។
ក៖ ចំ.....!
ខ៖ រៀបចំ.....!
ក៖ ចំ!ហើយចុះសាលាណុងបងរៀនជំនាន់ទីប៉ុន្មានច្រើនជំនាន់?
ខ៖ អត់ដឹងជំនាន់ទីប៉ុន្មាន។
ក៖ តែចូលទៅសាលាណុងវាមានលក្ខណៈម៉េចដែរ?
ខ៖
ចូលទៅលក្ខណៈមុនដំបូងសាលាវាតូចៗគត់ៗមួយកាដុបៗម៉ាដូចថាមួយខ្នងៗចឹងហាស។
ក៖ ដូចគត់លោកអីចឹងមែន?
ខ៖ ហ្នឹងហើយមួយខ្នងៗគេធ្វើមួយខ្នងៗហាស។
ក៖ ហើយឈើកំថ្មសារណុង?
ខ៖ ការរឹកជំនានណុងឈើខ្លះទៅថ្មខ្លះទៅ។
ក៖ ឈើខ្លះថ្មខ្លះ?
ខ៖ ហ្នឹងហើយ.....!
ក៖ អ៊ូ.....!
ខ៖ ប៉ុនសាលាខ្មុំចូលរៀនហ្នឹងមានឈើដល់ពេលឈើវាជ្រុះដូចថាវាពុកវាបាក់វាបែកជ្រុះក្បឿងជ្រុះអីទៅគេរៃចោលទៅគេធ្វើជាថ្ម។
ក៖ ហើយ.....?

ខ៖ ប្រកក្បឿង។
ក៖ អ៎!ហើយពេលដែរទៅរៀនសប្បាយទេជំនាន់ណុង?
ខ៖ ជំនាន់ណុងទៅរៀនសប្បាយហាសហត់សឹងអី។
ក៖ ជិះអីចឹងពីណាដល់ណាបង?
ខ៖ ជិះកង់ពីបឹងកុកទៅសាលា។
ក៖ បឹងកុកនៅជិតនេះហ្នឹង?
ខ៖ ជួនកាលដើរជំនាន់ណុងដើរហ្នឹងអត់មានកង់ជិះទេដើរ
ដើរទៅរៀនសិនដើរទៅរៀនដល់ទួលថ្មហោសដល់សាលាទួលថ្មបឋមនៅទួលថ្ម។
ក៖ ចឹង.....?
ខ៖ ចាំ.....!
ក៖
ហើយបងអើហ៎យដល់ពេលទៅរៀនបងពេលទៅសាលារៀនមានស្គាល់ណាគេទេមាន
ស្គាល់មិត្តភក្តិណាម្នាក់ដែរស្និទ្ធិស្នាលរឺមួយក៏ពីរបីនាក់ឡើងអីចឹងធ្លាប់មានទេមិ
ត្តភក្តិណាម្នាក់មានចាំឈ្មោះអត់?
ខ៖ មាន.....!
ក៖ មានហោសឈ្មោះអីដែរ?
ខ៖ ឈ្មោះចិន។
ក ឈ្មោះចិនហើយគាត់ស្រីក៏ប្រុស?
ខ៖ ស្រី.....។
ក៖ ស្រីហោស.....?
ខ៖ ចាំ.....!
ក៖ ហើយទៅរៀនតែងតែធ្វើអីជាមួយគ្នាមានសកម្មភាពអីខ្លះដែរចាំបានអត់?
ខ៖ មានលេងទៅលោតកៅស៊ូលោតអីហ្នឹង
លេងមឹកលេងអីហ្នឹងហាសហើយដល់ពេលមកផ្ទះទៅយើង
ធ្វើការទៅគេមានកង់ទៅគេឌុបយើងមកទៅជួនកាលទៅដើរមកទាំងអស់គ្នាម
កតែប៉ុណ្ណឹង។
ក៖ តែប៉ុណ្ណឹង?
ខ៖ ចាំ.....!
ក៖ អត់មានអីទៀតទេហោស?
ខ៖ អត់មានអីទេ។
ក៖ ដូចសរសេរអក្សរអីជាមួយគ្នាទៅលេងទឹកណាណីជាមួយគ្នា?
ខ៖ អត់ទេ.....!
ក៖ ធ្លាប់លេងទេ?
ខ៖
មិនដែរដើរផងកូនគេណុងមិនដែរដើរដែរចេញតែពីសាលាមកចូលផ្ទះដូចតែគ្នា។
ក៖ ហើយចុះមិត្តភក្តិហើយហ្នឹងបងរៀនចេះទាំងអស់គ្នាតើហ៊ី?
ខ៖ អើគេមិនសូវចេះទេគេរៀនឌុបគេឈប់តាំងពីថ្នាក់ទីបួនទីបីម៉េសទីបួន
គេឈប់រៀនតាំងពីទីបួនម៉េស ខ្ញុំរៀនបានទីប្រាំពីរបានចូលវិទ្យាល័យហ្នឹង
គេហ្នឹងគេឈប់មុន។
ក៖ អើបងពីកាលបងនៅក្មេងហាសអើម៉ាក់ប៉ាបងធូរធាហោសបង?
ខ៖ មិនធូរធាប៉ុន្មានទេគាត់អត់ដែរ។
ក៖ ពីកាលបងនៅក្មេងម៉ាក់បងធ្វើការរោងចក្របានប្រាក់ខែប៉ុន្មានបង?
ខ៖ អត់សូវអត់ដែរដឹងអត់ដឹងដែរ ដឹងប្រាក់ខែប៉ុន្មានអត់ដឹង។
ក៖ ហើយចុះបងអត់មានចាំរឿងរ៉ាវកាលនៅពីក្មេងអីទៀតទេណោះ?
ខ៖ អត់.....។
ក៖
អត់ទេណោះបងចាំហើយចុះតាំងពីក្មេងរហូតដល់ឥឡូវមានការផ្លាស់ប្តូរអីខ្លះបង?
ខ៖
ការផ្លាស់ប្តូរមានផ្លាស់ប្តូរម៉េចគ្រាន់តែថាយើងពេលនៅវ័កាលយើងអត់ទាន់វ័យ
ចំណាស់យើងធ្វើ

ការងារធ្វើការយកលុយមកចិញ្ចឹមកូនកើតដល់ពេលឥឡូវដល់ពេលវ័យចំណាស់ទៅធ្វើការលែងកើត។
ក៖ ចា៎.....!
ខ៖ នៅផ្ទះអត់ធ្វើអី។
ក៖ អត់រកអី?
ខ៖ ចា៎!អត់រកអី។
ក៖
ហើយអើចុះសួរមួយសំនួរទៀតដូចជាបងតាំងពីក្មេងរហូតដល់ឥឡូវបងចូលចិត្តមុខម្ហូបមួយណាជាងគេ?
ខ៖ មខុម្ហូបជាងគេហោស?
ក៖ ចូលចិត្តម៉ងអោយតែឆ្ងុយដឹងតែចង់ញ៉ាំុម៉ងហាស?
ខ៖ ចូលចិត្តជាងគេស្លម្ហូរ។
ក៖ ចា៎!សម្លម្ហូរ?
ខ៖ ចា៎.....!
ក៖ ហើយចុះអីទៀត?
ខ៖ បើឆាចូលចិត្តតើឆាប៉ងប៉ោះ។
ក៖ អ៎!ឆាប៉ងប៉ោះ?
ខ៖ ហ្នឹងហើយ.....!
ក៖ ចូលចិត្តម៉ង?
ខ៖ ចា៎.....!
ក៖ ម៉េចចឹង.....?
ខ៖ វាមានជាតិជូរ។
ក៖ ឆ្ងាញ់ហោស.....?
ខ៖ ចា៎!មានជាតិជូរឆ្ងាញ់។
ក៖ ឥឡូវហ្នឹងនឹកកូនអត់?
ខ៖ នឹកតើ.....។
ក៖
អ៎!នឹកកូនហើយអើតាំងពីក្មេងរហូតដល់ឥឡូវមីងចូលចិត្តចំរៀងនរណាអ្នកច្រៀងដែរចូលចិត្តចំរៀង មួយបទណា?
ខ៖ អត់.....!
ក៖ អត់ដែរចូលចិត្តចំរៀងទេ?
ខ៖ អត់.....!
ក៖ អ៎!ហើយចុះអ៊ុបើចុះកាលនៅពីក្មេងហាសធ្លាប់ទៅវត្តទៅអីអត់?
ខ៖ ទៅ.....!
ក៖ ទៅចុះពេលចូលឆ្នាំចូលអីគេធ្វើម៉េចទៅ?
ខ៖
ចូលឆ្នាំបាយសម្លមកប្រគេនលោកប្រគេនអីចឹងទៅមានគេលេងល្បែងកំសាន្តចឹងទៅណាស់។
ក៖ ដែរធ្លាប់រាំធុងបាសអីនៅវត្តអីទេ?
ខ៖ អត់ដែរផង។
ក៖ តាំងពីក្មេងហាស?
ខ៖ អត់អត់ដែរអត់ចង់។
ក៖ ថាលេងទាញ.....?
ខ៖ អត់ចេះអត់ចេះរាំ។
ក៖ ហើយចុះលេងទាញព្រាតអីដែរអត់?
ខ៖ អត់.....!
ក៖ អត់ដែរដែល?
ខ៖ អត់ដែរទាំងអស់។
ក៖ អើម៉េចចឹង?
ខ៖ អត់ដែរ.....។
ក៖ អត់ដែរលេងអីចឹងៗហោស?

ខ៖ ចា!អត់ដែរលេងៗ។
ក៖ ជាមួយមិត្តភក្តិក៏អត់ដែរហោស?
ខ៖ អត់ដែរលេងៗ។
ក៖ អ៎!ហើយចុះអើផ្ទះរបស់អ៊ីកាលអ៊ីនៅពីតូចផ្ទះអ៊ីមានរូបរាងម៉េចដែរ?
ខ៖
ផ្ទះហ្នឹងមានផ្ទះឈើប្រកស័ង្កសីដល់ពេលឥឡូវហ្នឹងមានផ្ទះខ្លួនឯងផងនៅជាមួយបងៗ។
ក៖ នៅជាមួយបងៗ?
ខ៖ ហ្នឹងហើយនៅជាមួយបងបង្អស់។
ក៖ ហេតុអីបាននៅជាមួយគាត់បងៗ?
ខ៖ បើខ្ញុំអត់មានដីមានផ្ទះដល់ពេលប្តីស្លាប់ទៅគាត់ហៅមកនៅជាមួយទៅ។
ក៖ ចឹងហើយចុះពីកាលបងនៅជាមួយប្តីមានដីមានផ្ទះអត់?
ខ៖ អត់មាន.....។
ក៖ អើហេតុអីបងៗ?
ខ៖ មកនៅផ្ទះម្តាយនៅផ្ទះម្តាយអត់មានដីមានផ្ទះនៅផ្ទះម្តាយ។
ក៖ ចឹងៗ.....?
ខ៖ នៅផ្ទះម្តាយនៅលិចណុងៗ។
ក៖ ហើយ.....?
ខ៖ ដល់ពេលគាត់ស្លាប់ទៅបងស្រីហៅមកនៅនៅកៀនវត្តហ្នឹងៗ។
ក៖
ចឹងហើយចុះអើបងហើយចុះនៅពេលដែរបងរៀបការជាមួយប្តីបងហើយរកមុខរបរអី?
ខ៖ អត់មានមុខរបរអីផងដំនាន់ណុងដាំផ្កា។
ក៖ ដាំផ្កា.....?
ខ៖ ចា!ដាំផ្កាលក់។
ក៖ ដាំផ្កាលក់ហោស?
ខ៖ ចា!ដាំផ្កាលក់។
ក៖ ដាំផ្កាអីគេខ្លះដែរ?
ខ៖ ដាំផ្កាចាន់ជូ សារ៉ា សេមាន់សេអីហ្នឹងៗ។
ក៖ អ៎!ដាំលក់?
ខ៖ ចា.....!
ក៖ ហើយបានលុយក្រៃលទេកាលណុងៗ?
ខ៖ អត់សូវបានប៉ុន្មានទេទៅលក់ម្សិលបានជួនកាលដប់ម៉ឺន ប្រាំពីប្រាំបីម៉ឺន។
ក៖ ហើយផ្កាឈូកអីដាំអត់?
ខ៖ ផ្កាឈូកដាំនៅបឹងៗ។
ក៖ ដាំនៅបឹងហោស?
ខ៖ ចា!ដាំនៅបឹងកាច់ទៅចងផ្កាបាច់ផ្កាអីបានប្រាំពីរប្រាំបីម៉ឺន។
ក៖ ចឹងកូនបងមានប៉ុន្មាននាក់បងៗ?
ខ៖ កូនបី.....។
ក៖ អ៎!កូនបីនាក់ហើយចុះកូនពៅគេនៅណា?
ខ៖ កូនពៅនៅរៀន។
ក៖ រៀននៅណាបងៗ?
ខ៖ រៀននៅអើឧត្តរនេះថ្នាក់ទីបួន ទីបួន ងៗ។
ក៖ ទីបួន ងៗ?
ខ៖ ហ្នឹងហើយទីបួន ងៗ។
ក៖ ហើយចេះអក្សរចេះអីទេកូនពៅ?
ខ៖ កូនពៅចេះតិចៗដែរ។
ក៖ ចឹងហោសអ៊ូ?
ខ៖
ម៉ែមិនសូវបានបង្រៀនបានអីអោយតែរៀនខ្លួនឯងតាមតំរិះខ្លួនឯងរៀនខ្លួនឯងរៀនគួររៀនអី។

កៈ អ៊ូ!បងហើយចុះពីកាលបងអើចាប់ដៃគ្នាជាមួយបងប្រុសហាស
ក្រៅពីដាំដុះហើយមានធ្វើអីទៀតទេដូចថាតស៊ូជាមួយគ្នា?
ខៈ អត់ទេ.....!
កៈ អ៊ូ!ហេតុអីក៏បងស្រឡាញ់គាត់?
ខៈ ស្រឡាញ់គាត់ពីមុនមកគាត់ធ្វើការនៅយាម។
កៈ គាត់ជាមនុស្សម៉េចទៅបានបងស្រឡាញ់គាត់ចឹងហាស?
ខៈ
នៅយាមនៅអីចឹងហាសគាត់មិនបានស្រឡាញ់ទេគាត់ស្លូតបូតគាត់អត់សូរចេះនិយាយចេះអី គាត់មិនសូរចេះនិយាយចេះអី។
កៈ ហើយចុះពេលការហើយគាត់ដែរជួយអីខ្លះបងទេ?
ខៈ ជួយស្រោចទឹកដុះស្រោចទឹកអី។
កៈ ដាំបាយធ្វើម្ហូបអីជួយអត់?
ខៈ ជួយ.....!
កៈ បោកខោអាវអី?
ខៈ បោកអីហ្នឹងជួយទាំងអស់។
កៈ គាត់ស្រឡាញ់ប្រពន្ធហោសបង?
ខៈ ជួយទាំងអស់ចា.....!
កៈ គាត់ស្រឡាញ់បងឯងខ្លាំងហោស?
ខៈ ចា.....!
កៈ អ៊ូ!ចឹងហើយចុះពេលបងឯងមានផ្ទៃពោះអីគាត់តែងតែជួយ.....?
ខៈ ជួយ.....!
កៈ មើលថែ.....?
ខៈ ហ្នឹងហើយជួយទៅពេទ្យទៅអីមើលការខុសត្រូវអីហ្នឹងហាស។
កៈ
ហើយចុះអើហើយចុះពេលកាលបងនៅរៀនហាសកាលនៅពីក្មេងបងតែងស្រមៃថាពេលរៀនចេះចឹង ចង់ធ្វើពេទ្យ
ចង់ធ្វើប៉ូលីសចង់ធ្វើអីចឹងដែរមានក្តីស្រមៃមួយទេ?
ខៈ ក្តីស្រមៃថារៀនចប់ទៅបានគ្រាន់ថារៀងធូរជាចង់ធ្វើដែរ។
កៈ ចង់ធ្វើអីគេដែរ?
ខៈ ចង់ធ្វើប៉ូលីស។
កៈ ចង់ធ្វើប៉ូលីស?
ខៈ ហ្នឹងហើយដល់ពេលរៀនអត់បានជ្រៅជ្រះអត់បានចូល។
កៈ ស្រឡាញ់ប៉ូលីសខ្លាំងហោស?
ខៈ ចា.....!
កៈ ចង់ធ្វើប៉ូលីសស្រី?
ខៈ ហ្នឹងហើយ.....!
កៈ ចង់ធ្វើប៉ូលីសតាំងពីតូចមកចង់ធ្វើប៉ូលីសម៉ង?
ខៈ ហ្នឹងហើយ.....!
កៈ ចា!ស្រឡាញ់ហាសណោះ?
ខៈ
ចា!ប៉ុនដល់ពេលរៀនអត់បានរៀនបានតិចរល់តែរៀនបានតិចពេកមើលម៉ែថាមើលម្តាយទៅអន់
ដូចថាគាត់មើលអើជីវភាពគាត់ពិបាកឈប់ទៅឈប់រៀនទៅ។
កៈ ចឹង.....!
ខៈ ចា.....!
កៈ ហើយដល់ពេលហើយចុះអើបងកាលពីក្រមុំធ្វើការនៅណាបង?
ខៈ អត់មានធ្វើការអីផងពីក្រមុំដាំដុះលក់រហូតហ្នឹង។
កៈ ដាំឥឡូវហ្នឹងនៅតែដាំមែន?
ខៈ ឥឡូវឈប់ដាំហើយ។
កៈ កើតអីបង?

ខ៖
វាល់តែគេយកដីយកអីដាក់ចាយដីចាយអីចឹងហាសណាស់លើកមុនដីពីរិហារវាទូលាយ តទ្បូរវាចង្អៀតចឹងហាសណាស់។
ក៖ ចា!ហើយចុះបើក្រៅពីដាំផ្កាបងចេះបោចរល្លី ធ្វើផ្តៅ.....?
ខ៖ អត់.....!
ក៖ ធ្វើល្អីអីទេ?
ខ៖ អត់អត់ៗចេះ។
ក៖ ក្បាញ្ញអីចេះអត់?
ខ៖ អត់.....!
ក៖ ក្បាញ្ញអត់ចេះដែរណោះបង?
ខ៖ ចា!អត់ចេះ។
ក៖ ចុះក្រុមគ្រួសាររបស់បងមាននរណាគេចេះលេងឧបករណ៍ភ្លេងទេ?
ខ៖ អត់មាន.....!
ក៖ លេងផ្លុំភ័យ ផ្លុំអីអត់ចេះទេ?
ខ៖ អត់មានអត់ចេះ។
ក៖ ហើយចុះក្រុមគ្រួសាររបស់បងមាននរណាគេចេះច្រៀង?
ខ៖ អត់.....!
ក៖ អ៎!អត់ចេះដែរហោស?
ខ៖ អត់ទាំងអស់។
ក៖ ចឹងហើយបងកើតទាន់សម័យប៉ុលពតអត់បង?
ខ៖ កើតទាន់.....។
ក៖ កើតទាន់ហោស?
ខ៖ ចា.....!
ក៖ កាលណុងបងអាយុប៉ុន្មានឆ្នាំ?
ខ៖ កាលណុងអាយុជ្រាំពីរជ្រាំបីឆ្នាំ។
ក៖ ជ្រាំពីរជ្រាំបីឆ្នាំ?
ខ៖ ចា.....!
ក៖ ហើយគេប្រើអីខ្លះដែរបង?
ខ៖ មានទៅប្រើអីផងដើររើសអើគួរស្រូវ។
ក៖ គួរស្រូវម៉េចទៅ?
ខ៖
គួរស្រូវគេដូចថាចាស់ៗច្រូតទៅចឹងហាសនៅអាគួរស្រូវរាជ្រុះនៅតាមភ្លឺស្រែតាមស្រែហ្នឹង យើងរើសមកដាក់ល្អីមក។
ក៖ ចឹង.....?
ខ៖ ចា.....!
ក៖ កាលណុងគេអោយធ្វើចឹងហោស?
ខ៖ ហ្នឹងហើយ.....!
ក៖ ចឹងហោសចឹង.....?
ខ៖ អាហ្នឹងគេមិនអោយធ្វើប៉ុនយើងទៅរើសទៅយកមកក។
ក៖ កាលណុងទាន់សម័យប៉ុល ពត?
ខ៖ ចា.....!
ក៖ ហើយចុះគេអោយហូបម៉េចវិញ?
ខ៖ បបរដាំបបរ។
ក៖ ជាមួយអី.....?
ខ៖ រាវមានជាមួយអីទេជាមួយអំបិលជួនកាលបបរទឹកបបរទទេហ្នឹង។
ក៖ ហើយពិបាកទេបងពិបាកញ៉ាំ១ទេ?
ខ៖ មើលតែក្រុមគ្រួសារខ្ញុំដូចអត់ពិបាកផង។
ក៖ ម៉េចចឹង.....?
ខ៖ វាដូចពិបាកអីញ៉ាំ១ទេគ្រាន់តែថាវាអត់មានអីនេះញ៉ាំ១វាមានតែអំបិលមានអំបិលចឹងទៅ។
ក៖ ហើយបងប្អូនទាំងអស់នៅជុំគ្នា?

ខ៖ ជុំគ្នា.....!
ក៖ អូ!សម័យហ្នឹងគេអត់ជំលាសម្តាយទៅផ្សេងកូនទៅផ្សឹងទេហោសបង?
ខ៖
អត់ផងកាលជំនាន់ណុងឪពុកម្តាយខ្ញុំគាត់នៅខាងគាត់នៅអើធ្វើចុងភៅចឹងហាស
ធ្វើចុងភៅធ្វើម្ហូបដាំបាយដាំអីចឹងហាសណាស់ដល់ពេលចឹងអត់ជំលាសអត់ជំលាសទៅណាផងគ្រាន់តែខ្លាចយើងវ័យកុមារ
គ្រាន់តែជំលាសយើងទៅឆ្ងាយពីម៉ែឪប៉ុនដូចអត់យកទៅណាទៅណីផង។
ក៖
ហើយចុះក្រុមគ្រួសាររបស់បងអត់មាននរណាគេស្លាប់នៅក្នុងសម័យណុងទេហោស?
ខ៖ អត់មានទេ។
ក៖ ហើយចុះអើចឹងខ្ញុំចង់សួរពីឆាកជីវិតរបស់បងវិញ
តើបងមានឆាកជីវិតជួបការទុក្ខលំបាកអីខ្លះនៅក្នុងជីវិតរបស់បង
បងអាចនិយាយចេញមកអោយអើពួកយើងបានដឹងថាបងលំបាកអីខ្លះចឹងហាសបង?
ខ៖ ដូចអត់មានផងអត់មានទុក។
ក៖ នៅពេលដែរប្តីស្លាប់ទៅពិបាក.....?
ខ៖
ប៉ុនបើប្តីស្លាប់ទៅពិបាកត្រង់ដូចថាខ្ញុំចាស់ហើយរួចទៅអត់មានការងារធ្វើអត់មានលុយមានកាក់អីទិញម្ហូបទិញបាយអីចឹងទៅណាស់ទិញអង្ករទិញអី។
ក៖ ហើយចុះនៅជាមួយបងស្រីបងស្រីផ្តល់អោយហោស?
ខ៖ អត់ផង.....។
ក៖ នៅជាមួយគាត់នៅរបៀបម៉េចបង?
ខ៖ នៅតែផ្ទះតើដល់ពេលបាយញ៉ាំខ្លួនឯង។
ក៖ ត្រូវរកលុយធ្វើខ្លួនឯង?
ខ៖ ហ្នឹងហើយ.....!
ក៖ ហើយចុះកូននៅម៉ាឡេផ្ញើរលុយអោយម្តាយទេ?
ខ៖ អត់.....។
ក៖ ម៉េចចឹងបង?
ខ៖ អត់ដែរផ្ញើរផង។
ក៖ ហើយចុះកូនអើកូនរបស់បងបន្ទាប់ទៀតហោសធ្វើអីដែរ?
ខ៖ ទីពីរហ្នឹងវារៀនបាក់ឌុបជាប់ប៉ុនអត់បានរៀនបន្តដល់ការទៅ
ទៅរត់តុរត់តុរោងការគេទៅអីទៅ។
ក៖ ហើយគាត់ផ្តល់លុយអោយបងដែរទេ?
ខ៖ អត់ចាយតែខ្លួនឯងហ្នឹងមិនគ្រប់ផង។
ក៖ ចំា!ហើយចុះបងនៅចិញ្ចឹមកូនពៅមួយទៀត?
ខ៖ កូនពៅហ្នឹងនៅជាមួយអ៊ីអ៊ីចិញ្ចឹមទៅជួយលក់អ៊ីវានៅមាត់ទន្លេទៅ
ជួយលក់ទឹកអំពៅគាត់លក់ទឹកអំពៅនុំកាឆាយនុំអីចឹងហាស
ជួយលក់អ៊ីទៅយកលក់បានអ៊ីអោយលុយទៅរៀនទៅអីទៅ
ញ៉ាំបាយជាមួយអ៊ីហ្នឹងទៅតែខ្ញុំទេ។
ក៖ តែម្នាក់ឯង.....?
ខ៖ ហ្នឹងហើយតែឯងហ្នឹង។
ក៖ ហើយមកនៅវត្តហ្នឹងទៅម៉េចក៏ម៉េច?
ខ៖
អត់ទេខ្ញុំអត់នៅវត្តផងគ្រាន់តែថាមកទំនេរៗវាក្តៅស្អុះពោកហ្នឹងមកផ្ទះវាស័ង្កសីហ្នឹងហោស ប្រកស័ង្កសីវាក្តៅពោកហ្នឹងផ្ទះមកអង្គុយលេងទៅ អង្គុយលេង។
ក៖ ហើយពីមុនបងដាំតែផ្កា?
ខ៖ ចំា.....!
ក៖ ដល់ពេលឈប់ដាំផ្កាមានធ្វើអីទៀតទេបង?
ខ៖ មានធ្វើអី។

កៈ ហើយចុះអត់ធ្វើការ.....?
ខៈ កាលមួយរឹកដាំផ្កាហ្នឹងដល់ពេល
កាលរឹកយើងដាំផុតពីផ្កាហ្នឹងទៅមានប្តីយើងធ្វើការធ្វើអីចឹងទៅ
ធ្វើការសណ្ឋាគារសណ្ឋាអីចឹងទៅណាស់។
កៈ បងធ្លាប់ធ្វើហោស?
ខៈ ចំា.....!
កៈ ចុះឥឡូវធ្វើអត់កើតទៀតមែន?
ខៈ ឥឡូវវាដូចថាវាជ្រាយដូចអត់សូវមានកំលាំងដៃហ្នឹងធ្វើ
អត់មានកំលាំងដៃយូរចេះវាអត់សូវមានកំលាំងម៉ងហាសអត់ដូចពីមុនទេពីមុន
វាដូចថាយើងនៅមានកំលាំងមានកំហែង
ធ្វើទៅលើកទៅដៃយើងវាអត់ទន់អត់ជ្រាយដល់ពេលចឹងដៃយើងហ្នឹងជ្រាយមួយ
ចំហៀងដៃជ្រាយខាងឆ្វេងហ្នឹងហាសវាទន់ម៉ង
ទើបឥឡូវទេបានកាច់ចេះបានហោសលើកមុនកាច់អត់បានទេ។
កៈ រឹងមែន.....?
ខៈ រឹងឈឺម៉ងវាឆ្នឹងហ្នឹងឈឺម៉ងហាស។
កៈ ហើយបងឈឺហ្នឹងប៉ុន្មានឆ្នាំហើយ?
ខៈ ឈឺហ្នឹង២០១៨ ខែ៥ឈឺខែសំពាគសរសៃឈាមបេះដូងហ្នឹងហាស។
កៈ ហេតុអីបង?
ខៈ ខែ៥.....។
កៈ ហេតុអីក៏កើតជំងឺមួយហ្នឹងដឹងទេ?
ខៈ អត់ដឹងដែរ។
កៈ គ្រូពេទ្យប្រាប់ថាម៉េចទៅ?
ខៈ គ្រូពេទ្យទៅជួសឈាមទៅអូសអេកូអីមើលទៅថាសំពាកហ្នឹង
សំពាគសរសៃឈាមប៉ុនឆាប់ហត់
ដើរហត់និយាយហត់ឆាប់ហត់ម៉ងជ្រៀនជាងគេធ្វើទុកខ្លាំងជាងគេហ្នឹង.....។
កៈ ចុះឥឡូវហ្នឹងនិយាយហត់អត?
ខៈ ហត់ដែរប៉ុន្តហត់តិចៗអើធ្វើការងារអីអត់នេះ.....!
កៈ អត់ដូចមុនហោស?
ខៈ ចំា!វាអត់ដូចមុនទេតែដើរក៏ហត់ដែរ។
កៈ ចំា.....!
ខៈ និយាយទៅញ៉ាុបាយក៏ហយត់ដែរ។
កៈ ចំាបង.....!
ខៈ ចំា.....!
កៈ
ហើយចុះអើចឹងជាចុងក្រោយមានពាក្យពេជ្រផ្តាំផ្ញើរដល់កូនរបស់បងបើសិនជា
គាត់បានលឺសម្តីបង បងចង់អោយគាត់ខំប្រឹងអីហើយអោយគាត់ជៀសវៀង?
ខៈ កំពុងអោយវារកការងារណាអោយបានជាប់លាប់
ហើយដឹងថាធ្វើការប៉ុនវាដាក់ទហ៊ានប៉ុនដឹងជាប់ដឹងអត់?
កៈ មានពាក្យពេជ្រអីផ្តាំផ្ញើរដល់កូនទាំងអស់របស់បងហាសណាស់?
ខៈ អត់មាន.....។
កៈ អោយគាត់ខំប្រឹងអី?
ខៈ
ក្រាន់តែអោយអាពៅហ្នឹងខំប្រឹងរៀនហើយទៅពីរហ្នឹងអោយបានដាក់ធ្វើការងារ
និយាយអោយបានជាប់ប្រលងជាប់ប្រលងអោយបានជាប់
អោយឆាប់ជាប់ប្រលងទាហ៊ានហ្នឹងអោយជាប់បានអោយបានមានមុខមានអី។
កៈ ហើយចុះកូនបង?
ខៈ កូនបង.....!
កៈ ចង់ផ្តាំផ្ញើរអី?
ខៈ
ចង់ផ្តាំផ្ញើរអោយចង់អោយកូនបកមកវិញដែរណាងហាសចង់អោយបកមកវិញ
ម៉ែឈឺចឹងណាស់ ចង់អោយកូនឆាប់វិលមកវិញចឹងហាស។

កៈ នឹកកូនអត់?
ខៈ ចា៎.....!
កៈ
អ៊ូចា៎!ហើយមានពាក្យអីអោយគាត់ជៀសវៀងអីក្រឿងញៀនអីអត់អោយមានទេហ៊ី?
ខៈ ជៀសវៀងក្រឿងញៀនក្រឿងអីហ្នឹងអោយជៀសវៀងអោយផុតអោយអស់។
កៈ
ចា៎!ចឹងជាចុងក្រោយអរគុណបងច្រើនមែនទែនដែរបានអនុញ្ញាតិអោយរូបនាងខ្ញុំដាក់ទៅក្នុងវេបសាយសាលាសង្ឃឹមថាបងបានស្តាប់សម្ដីបង
អើអោយពួកគាត់ខំប្រឹងធ្វើអ្វីដែរបងបានផ្ទើរណាស់បងណាស់?
ខៈ ចា៎.....!
កៈ អរគុណច្រើន។